# ក្លិនសីលក្លិនផ្កា

(បទពាក្យ ៧)

ពាក្យសុភាសិតមានផលល្អ ដូចផ្កាមានពណ៌ក្រអូបខ្លាំង
ថាផងធ្វើផងប្រើកម្លាំង សម្រាំងធ្វើតាមយកផលល្អ ។
មាល័យរូតក្រងផ្កាបន្ទាន់ ឲ្យអស់គ្រប់គ្រាន់ពីគំនរ
យើងត្រូវរូតសាងកុសលធម៌ មនុស្សសត្វនិករតែងតែស្លាប់ ។
ក្លិនចន្ទន៍ក្រិស្នាផ្កាម្លិះ ក្លិននេះច្រាសខ្យល់មិនដែលធ្លាប់
ក្លិននៃសប្បុរសស្រស់ចំណាប់ ផ្សាយផ្សព្វច្រាសខ្យល់សព្វទិសា។
ក្លិនផ្កាទាំងអស់មិនសំខាន់ ឧប្បលក្លិនចន្ទន៍ ឬក្រិស្នា
ឯក្លិននៃសីលក្ខុបអស្ចារ្យ លើសក្លិននានាក្នុងលោកីយ៍ ។
ក្លិនចន្ទន៍ក្រិស្នានោះតិចតួច ប្រដូចនិងគុណធម៌ដទៃ
ក្លិនសីលវិសេសវិសាលក្រៃ ក្រអូបសុះសាយដល់ទេវា ។
ពួកមារមិនបាននូវគំនិត នៃអ្នកសីលពិតធម្មវិហារ
ដែលដឹងប្រព្រៃនូវមាគ៌ា ព្រោះមារមិនបានជួបផ្លូវត្រង់ ។
ធម្មតាផ្កាឈូកដុះក្បែរផ្លូវ ក្នុងពួកសម្រាមយ៉ាងគម្រង់
តែមានពណ៌ល្អក្រអូបឆ្ងង់ ជាទីមនោរម្យជននានា ។
ដូចជាសាវ័កព្រះគោត្តម ទោះកើតក្នុងក្រុមជនអន្ធការ
តែល្បីរុងរោចន៍ដោយប្រាជ្ញា នៅក្នុងបណ្តាពាលនិករ ៕